# សេចក្តីថ្លែងការណ៍រួម
## យោបល់ពីប្រជាពលរដ្ឋនៃអាងទន្លេមេគង្គសម្រាប់កិច្ចប្រជុំកំពូលលើកទី ៣ នៃគណៈកម្មការទន្លេមេគង្គ

*ភ្នំពេញ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៨*

សេចក្តីថ្លែងការណ៍នេះអំពាវនាវដល់រដ្ឋាភិបាលនៃតំបន់ទន្លេមេគង្គក្រោមនិងគណៈកម្មការទន្លេមេគង្គឲ្យគោរព និងការពារសិទ្ធិរបស់ប្រជាពលរដ្ឋដែលជីវភាពរស់នៅរបស់ពួកគាត់បាន និងរងការប៉ះពាល់ដោយសារការសាងសង់ទំនប់វារីអគ្គិសនីនៅតាមដងទន្លេមេគង្គ ព្រមទាំងសូមឲ្យការពារប្រព័ន្ធអេកូឡូស៊ីទន្លេនេះផងដែរ និងដើម្បីថ្លែងពីជំហររបស់អង្គការសង្គមស៊ីវិលនៅកម្ពុជា ទាក់ទងនឹងការសាងសង់ទំនប់។

សេចក្តីថ្លែងការណ៍នេះ នឹងគូសបញ្ជាក់ពីផលប៉ះពាល់ពីការប្រែប្រួលនេះ មកលើរបរចិញ្ចឹមជីវិតរបស់ប្រជាជននៅតាមដងទន្លេមេគង្គ និងបឹងទន្លេសាប បញ្ហានានាដែលទាក់ទងនឹងការធ្វើសេចក្តីសម្រេច និងដំណើរការសាងសង់ទំនប់នានានៅភាគខាងលើនៃទន្លេមេគង្គ ការសម្រេចរបស់កម្ពុជាអំពីទំនប់របស់ខ្លួននៅលើដងទន្លេមេនៃទន្លេមេគង្គ និងបន្ទាប់មកបង្ហាញពីជំហររបស់អង្គការសង្គមស៊ីវិលអំពីទំនប់នានាដែលបានសាងសង់នៅពេលថ្មីៗនេះ និងគម្រោងទំនប់ដែលបានស្នើឡើងថ្មីៗនេះផងដែរ។

<u>ផលប៉ះពាល់នៃទំនប់វារីអគ្គិសនីនៅភាគខាងលើនៃទន្លេមេគង្គមកលើប្រជាជនកម្ពុជា (បទពិសោធន៍របស់ប្រជាជន)</u>

ទំនប់សាយ៉ាប៊ូរី ដុនសាហុង និងប៉ាក់បេង ស្ថិតក្នុងចំណោមគម្រោងថាមពលវារីអគ្គិសនីចំនួន ១១ ដែលបានស្នើឡើងសម្រាប់ការសាងសង់លើដងទន្លេមេនៃទន្លេមេគង្គ ក្នុងនោះរួមមាន ទំនប់ចំនួន ៩ ក្នុងប្រទេសឡាវ និង ២ នៅកម្ពុជា។ ទំនប់សាយ៉ាប៊ូរី និងដុនសាហុង កំពុងស្ថិតក្នុងការសាងសង់ ចំណែកទំនប់ប៉ាក់បេង បានបញ្ចប់ដំណើរការពិគ្រោះយោបល់ជាមុន នៅក្រោមនីតិវិធីរបស់គណៈកម្មការទន្លេមេគង្គ សម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង(PNPCA)។ សូម្បីគម្រោងទាំងនេះនៅពុំទាន់បានដាក់ឲ្យដំណើរការនៅឡើយក៏ដោយ ការប្រែប្រួលជាច្រើនត្រូវបានសង្កេតឃើញរួចមកហើយចំពោះរបបជលសាស្រ្ត និងអេកូឡូស៊ីនៃទន្លេមេគង្គ។ វាជាការលំបាកខ្លាំងណាស់ក្នុងការប្រមើលមើលផលប៉ះពាល់នានាដែលបង្កមកលើអេកូឡូស៊ីនៃទន្លេមេគង្គ និងរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋជាច្រើនលាននាក់ ប្រសិនបើគម្រោងដែលបានគ្រោងឡើងនេះត្រូវបានដាក់ឲ្យអនុវត្ត។

ការប្រែប្រួលរបបជលសាស្រ្តនៃទន្លេមេគង្គ មិនត្រឹមតែបង្កការប៉ះពាល់មកលើប្រព័ន្ធអេកូឡូស៊ីប៉ុណ្ណោះទេ ប៉ុន្តែក៏មកលើរបរចិញ្ចឹមជីវិតរបស់សហគមន៍ផងដែរ។ ការថយចុះនៃផលនេសាទ ដែលជាប្រភពចំបងនៃស្បៀងអាហារ និងរបរចិញ្ចឹមជីវិត ក្រៅពីការដាំដំណាំ និងការប្រមូលអនុផលព្រៃឈើនៅក្នុងព្រៃ បានធ្វើឲ្យសហគមន៍កាន់តែក្រីក្រថែមទៀត។ បើយោងតាមសហគមន៍នៅក្រចេះ[1] ការថយចុះនៃផលនេសាទ បានបង្ហាញឲ្យឃើញជាក់ស្តែងតាមរយៈត្រីប្រភេទខ្លះ ជាពិសេស ត្រីប៉ាស៊ីអ៊ី (*Mekonginaerythrospila*) ដែលមានតែនៅក្នុងខេត្តក្រចេះ និងស្ទឹងត្រែង នៃប្រទេសកម្ពុជា ដែលបានថយចុះជាច្រើន ។

ការប្រែប្រួលមិនទៀងទាត់នៃរបបទឹក បានធ្វើឲ្យគុណភាពទឹកធ្លាក់ចុះ និងបាននាំឲ្យមានការថយចុះកម្រិតកំពស់ទឹក ដែលប៉ះពាល់ជាខ្លាំងដល់សុខភាពរបស់ប្រជាជន និងការស្រោចស្រព។ វាបង្កឲ្យមានការថយចុះកម្រិតកំពស់ទឹក ការថយចុះនៃបរិមាណដីល្បាប់ បានបង្កការប៉ះពាល់អវិជ្ជមានដល់ការអភិវឌ្ឍកសិកម្មរបស់ប្រជាពលរដ្ឋ។ លើសពីនេះ ការប្រែ

---

[1] សមាជិកសហគមន៍មកពីខេត្តក្រចេះ បានចែករម្លែកការសង្កេតរបស់គាត់អំពីការប្រែប្រួលនៃទន្លេមេគង្គ នៅក្នុងវេទិកាសាធារណៈអំពីទន្លេមេគង្គ ដែលរៀបចំឡើងកាលពីថ្ងៃទី ២០ ខែមីនា ២០១៨ នៅកាន់ធឺរ ប្រទេសវៀតណាម។

ប្រែប្រួលមិនទៀងទាត់នៃបរិមាណទឹក បានធ្វើឲ្យមានការហូរច្រោះដី ភាគច្រើននៅតាមកន្លែងនានា ដែលស្ថិតនៅជិតអាងទឹក ដែលកើតចេញពីការសាងសង់ទំនប់នោះ។ ការហូរច្រោះដី នៅតាមច្រាំងទន្លេ គឺជាផលវិបាកមួយបន្ថែមទៀត បណ្តាលពីការបើកទឹកយ៉ាងច្រើនចេញពីទំនប់ ដែលធ្វើឲ្យថយចុះដីកសិកម្ម។ ជាលទ្ធផល សកម្មភាពដាំដំណាំ នៅតាមច្រាំងទន្លេ ត្រូវបានរាំងស្ទះទាំងស្រុង។ ប្រការទាំងនេះបានបង្កការប៉ះពាល់ធ្ងន់ធ្ងរមកលើសកម្មភាពកសិកម្មរបស់ប្រជាជន ដែលមានបរិចិញ្ចឹមជីវិតពឹងផ្អែកភាគច្រើនលើទន្លេនេះ។ សកម្មភាពដាំដំណាំរបស់ប្រជាជននៅតាមដងទន្លេ និងទិន្នផលដំណាំកំពុងធ្លាក់ចុះ រួមផ្សំនិងការថយចុះជាច្រើននៃផលនេសាទ ជាហេតុធ្វើឲ្យមានការបាត់បង់ជាច្រើនចំពោះប្រភពប្រាក់ចំណូល ដូច្នេះតម្រូវឲ្យសមាជិកខ្លះនៃសហគមន៍ធ្វើចំណាកស្រុកដើម្បីស្វែងរកការងារផ្សេង។

សហគមន៍ពីបឹងទន្លេសាប មានកង្វល់ដោយឡែកអំពីផលប៉ះពាល់ដែលបង្កដោយទំនប់វារីអគ្គិសនីនៅភាគខាងលើនៃទន្លេមេគង្គ ដោយសារតែទន្លេមេគង្គ និងបឹងទន្លេសាប មានទំនាក់ទំនងគ្នាជិតស្និទ្ធ និងគាំទ្រគ្នាទៅវិញទៅមក។ ដូចគ្នានឹងទន្លេមេគង្គផងដែរ របបទឹកបឹងទន្លេសាបបានប្រែប្រួលជាខ្លាំង ដោយសារតែសារការសាងសង់ទំនប់នៅក្នុងអាងទន្លេមេគង្គ។ ប្រការនេះក៏បង្កការប៉ះពាល់ចំពោះផលស្តុកមច្ឆជាតិនៅក្នុងបឹងនេះ និងផលិតកម្មស្រូវនៅតំបន់ជុំវិញផងដែរ។ ឧទាហរណ៍ជាក់លាក់ បង្ហាញតាមរយៈបានថយចុះជាខ្លាំងនៃប្រភេទត្រីនានាដែលធ្លាប់ត្រូវបានប្រើប្រាស់សម្រាប់ផលិតប្រហុក ដែលជាអាហារតាមប្រពៃណីដ៏សំខាន់មួយរបស់ប្រជាជនកម្ពុជា មកដល់កម្រិតមួយដែលពុំមានត្រីគ្រប់គ្រាន់សម្រាប់ផលិតស្បៀងប្រភេទនេះ។[2] របបជលសាស្ត្រនៃបឹងទន្លេសាប ក៏បានផ្តល់ជាប្រភពទឹកសម្រាប់ផលិតកម្មស្រូវផងដែរសម្រាប់សហគមន៍ដែលរស់នៅជិតបឹងនេះ។ បរិមាណទឹកតិចជាងមុននៃបឹងទន្លេសាប បាននាំឲ្យមានការពន្យាពេលឬការបោះបង់ចោលការផលិតស្រូវដោយសហគមន៍ខ្លះ ជាមួយផលវិបាកមិនត្រឹមតែការបាត់បង់ផលស្រូវប៉ុណ្ណោះទេ។

<u>កង្វល់ចំបងនៃទំនប់ដែលបានស្នើសម្រាប់សាងសង់នៅដងទន្លេមេនៃទន្លេមេគង្គក្នុងប្រទេសកម្ពុជា</u>

រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសជាផ្លូវការថា នឹងធ្វើការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើសំណើគម្រោងថាមពលវារីអគ្គិសនីសំបូរ និងស្ទឹងត្រែង នៅលើដងទន្លេមេនៃទន្លេមេគង្គ (RGC, 2016)។ ប្រសិនបើសាងសង់ ទំនប់សំបូរនឹងក្លាយជាទំនប់ថាមពលវារីអគ្គិសនីធំជាងគេនៅកម្ពុជា និងក្នុងអាងទន្លេមេគង្គក្រោម។ ប្រសិនបើទំនប់នេះបានសាងសង់មែននោះ វានឹងបង្កការប៉ះពាល់អវិជ្ជមានមកលើសន្តិសុខស្បៀង របរចិញ្ចឹមជីវិត និងផលិតកម្មកសិកម្ម។ ទំនប់នេះនឹងកាត់ផ្តាច់ចរាចរត្រី និងទំនាក់ទំនងអេកូឡូស៊ីដែលមានសារៈសំខាន់ជាអាយុជីវិត រវាងភាគខាងលើនៃទន្លេមេគង្គ បឹងទន្លេសាបនៅកម្ពុជា និងដែនដីសណ្តទន្លេមេគង្គក្នុងប្រទេសវៀតណាម។

លើសពីនេះ ព័ត៌មានពីរបាយការណ៍សិក្សាលទ្ធភាពនៃស្ថានីយ៍ថាមពលវារីអគ្គិសនីសំបូរបានបង្ហាញថា សំណើទំនប់សំបូរនឹងបង្កការប៉ះពាល់ដោយផ្ទាល់ដល់ប្រជាជនចំនួន ១៩.០៣៤នាក់។ ប្រជាពលរដ្ឋទាំងនេះនឹងត្រូវផ្លាស់ទីលំនៅទៅកន្លែងផ្សេង ដោយសារទីលំនៅបច្ចុប្បន្នរបស់ពួកគេ និងធនធានធម្មជាតិ នឹងត្រូវលិចលង់ជាអចិន្ត្រៃយ៍នៅក្នុងអាងដែលកើតឡើងដោយសារទំនប់នេះ (Liu, 2008)។ ការសិក្សាវិទ្យាសាស្ត្រមួយដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍នេសាទទឹកសាប (IFReDI) នៅឆ្នាំ២០១២ បានប៉ាន់ប្រមាណថា ទិន្នផលត្រី និងវារីសត្វនានាដទៃទៀត នឹងថយចុះ ១៦% - ៣០% ឬ ៩៨.០០០ - ១៨២.០០០ តោន ប្រសិនបើសំណើទំនប់នេះត្រូវសាងសង់។ សំណង់អភិវឌ្ឍន៍ថាមពលវារីអគ្គិសនី និង ទីតាំងដែលជាប់ពាក់ព័ន្ធនឹងការសាងសង់ទំនប់ទាំងនេះ នឹងបង្កការប៉ះពាល់អវិជ្ជមានមកលើប្រភេទត្រីដែលធ្វើចរាចរទៅកាន់ទីកន្លែងពងកូនសំខាន់ៗនៃប្រភេទទាំងនោះ។ គ្មានដំណោះស្រាយជោគជ័យណាមួយសម្រាប់កូន

[2] ការសង្កេតមួយចែករំលែកដោយតំណាងពីសហគមន៍នេសាទមកពីខេត្តពោធិសាត់ នៅក្នុងវេទិកាសាធារណៈស្តីពីទន្លេមេគង្គ ដែលរៀបចំឡើង នៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៨ នៅកាន់ធឺរ ប្រទេសវៀតណាម។

ត្រីតូចៗ នៅខ្សែទឹកខាងក្រោមនៃទំនប់ឡើយ (IFReDI, 2017)។ លំហូទឹកពីទន្លេមេគង្គនឹងប្រែប្រួល ដែលនឹងមានផលប៉ះពាល់ដ៏មហន្តរាយចំពោះកម្រិតកំពស់ទឹកនៅក្នុងបឹងទន្លេសាប។ មានការប៉ាន់ប្រមាណផងដែរថា កម្រិតកំពស់ទឹកនឹងកើនឡើង ១,២ម នៅរដូវប្រាំង និងថយចុះ ១ ម នៅរដូវវស្សា (Sushu et al, 2010)។

## ស្ថានភាពនៃការអភិវឌ្ឍទំនប់ថាមពលវារីអគ្គិសនីនៅតាមដងទន្លេមេនៃទន្លេមេគង្គ

ទំនប់វារីអគ្គិសនី ដែលបានសាងសង់មកទល់បច្ចុប្បន្ននៅលើដងទន្លេមេនៃទន្លេមេគង្គបានធ្វើឡើង ទោះបីមានភាពខ្វះចន្លោះជាច្រើននៅក្នុងដំណើរការធ្វើសេចក្តីសម្រេច និងកង្វះតម្លាភាពនៃព័ត៌មាន និងការពិគ្រោះយោបល់ជាមួយសហគមន៍រងគ្រោះ នៅក្នុងអាងទន្លេមេគង្គក៏ដោយ។

ទំនប់សាយ៉ាប៊ូរី បានរងការរិះគន់ដោយសហគមន៍រងការប៉ះពាល់ និងអ្នកពាក់ព័ន្ធនានានៅទូទាំងតំបន់នេះ តាមរយៈដំណើរការ PNPCA ដែលបានបង្ហាញច្បាស់ពីលក្ខខណ្ឌតម្រូវឲ្យមានការពិគ្រោះយោបល់ជាមុនជាមួយប្រទេសនៅតាមដងទន្លេនេះ មុននឹងចាប់ផ្តើមគម្រោង។ សូម្បីមានការបង្ហាញច្បាស់នូវកង្វល់ និងការឆ្លើយតបដ៏ខ្លាំងក្លាពីប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ ជំទាស់នឹងការសាងសង់ទំនប់នេះ នៅលើដងទន្លេមេនៃទន្លេមេគង្គ និងសំណើឲ្យមានការពន្យារទុករយៈពេលដប់ឆ្នាំ នូវការសាងសង់ទំនប់ និងរង់ចាំការសិក្សាបន្ថែមទៀត ដែលរួមទាំង ការវាយតម្លៃនៅទូទាំងអាងទន្លេនេះក៏ដោយ រដ្ឋាភិបាលឡាវនៅតែបន្តឈានទៅអនុវត្តគម្រោងនេះ។ នេះជាភស្តុតាងបង្ហាញច្បាស់ថា កង្វល់នានាដែលលើកឡើងក្នុងអំឡុងនៃនីតិវិធីពិគ្រោះយោបល់ជាមុន ពុំមានឥទ្ធិពលជាប្រយោជន៍ណាមួយមកលើការធ្វើសេចក្តីសម្រេចឡើយ។

លំហសម្រាប់អង្គការសង្គមស៊ីវិលនៅក្នុងការពិគ្រោះយោបល់ជាសាធារណៈ ជាពិសេស អំពីគម្រោងទំនប់វារីអគ្គិសនី នៅលើដងទន្លេមេ និងដៃនានានៃទន្លេនេះ នៅតែមានកម្រិតកំណត់ និងមិនបានបើកចំហទូលាយសម្រាប់អ្នកដែលកំពុងធ្វើការដោយផ្ទាល់ជាមួយសហគមន៍រងគ្រោះនៅតាមមូលដ្ឋានឡើយ។ បទពិសោធន៍ជាមួយទំនប់សាយ៉ាប៊ូរី ដុនសាហុង និងប៉ាក់បេង បង្ហាញថា ដំណើរការធ្វើសេចក្តីសម្រេចចិត្តមិនបានបើកចំហទូលាយសម្រាប់ការពិគ្រោះយោបល់ជាសាធារណៈឡើយ។ អង្គការសង្គមស៊ីវិលមួយចំនួនតូច បានទទួលការអញ្ជើញចូលរួមនៅក្នុងការពិគ្រោះយោបល់ តាមរយៈការជូនដំណឹងបន្ទាន់ ដែលបង្កជាការលំបាកសម្រាប់ការចូលរួមពីសំណាក់សហគមន៍រងគ្រោះ និងអង្គការសង្គមស៊ីវិលដែលពាក់ព័ន្ធ ដែលកំពុងធ្វើការនៅតាមមូលដ្ឋាន ក្នុងការចូលរួមនៅក្នុងការពិគ្រោះយោបល់។

ទោះជាយ៉ាងណាក៏ដោយ ទំនប់សាយ៉ាប៊ូរី និងដុនសាហុង កំពុងស្ថិតនៅក្នុងការសាងសង់ ហើយព័ត៌មានពេញលេញអំពីគម្រោងនេះ ដែលរួមទាំង សេចក្តីពិស្តារអំពីរចនាបថគម្រោង និងការវាយតម្លៃនានា ដែលបង្ហាញវិធានការនានាដូចជា ច្រកសម្រាប់ត្រីឆ្លងកាត់ ដែលនឹងទប់ស្កាត់ការធ្វើឲ្យខូចវិស័យនេសាទនៅក្នុងអាងទន្លេមេគង្គ និងផលប៉ះពាល់ដទៃទៀតមកលើប្រព័ន្ធអេកូឡូស៊ីទន្លេនេះ នៅពុំទាន់បានប្រកាសផ្សព្វផ្សាយជាសាធារណៈឡើយ ទោះបីមានសំណើជាបន្តបន្ទាប់ពីសហគមន៍ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធដទៃទៀតក៏ដោយ។

## ជំហររបស់អង្គការមិនមែនរដ្ឋាភិបាល

យើងជាអង្គការសង្គមស៊ីវិល រួមជាមួយសហគមន៍រងគ្រោះដោយសារទំនប់ ដែលធ្វើការខាងផ្នែកអភិបាលកិច្ចទឹកនៅទូទាំងប្រទេស សូមស្នើដល់រដ្ឋាភិបាលនៅបណ្តាប្រទេសក្នុងអាងទន្លេមេគង្គ និងគណៈកម្មការទន្លេមេគង្គ ធ្វើការដោះស្រាយកង្វល់ និងការទាមទារដូចតទៅ៖

- ការរៀបចំផែនការអភិវឌ្ឍន៍ថាមពលជាតិ គួរតែតម្រូវឲ្យមានការចូលរួមជាសាធារណៈ ទាំងបុរស និងស្ត្រី គ្រប់វ័យ ជាពិសេសសហគមន៍រងគ្រោះ នៅក្នុងដំណើរការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ ដើម្បីធានាថាផែនការនោះ ពុំបង្កផលប៉ះពាល់អវិជ្ជមានណាមួយមកលើបរិស្ថាន ធនធានធម្មជាតិ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។ យើងទទួលស្គាល់ពីតម្រូវការអគ្គិសនី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច នៅក្នុងប្រទេសយើង និងក្នុងតំបន់នេះ ទោះជាយ៉ាងណាក៏ដោយ ផែនការទាំងនោះគួរចាត់ជាអាទិភាពនូវការបំពេញតម្រូវការថាមពលរបស់ប្រជាពលរដ្ឋមូលដ្ឋាន មិនមែនការផលិតអតិរេកអគ្គិសនីសម្រាប់នាំចេញទៅក្រៅប្រទេសឡើយ។ ផែនការទាំងនោះ គួរតែរៀបចំឡើងសម្រាប់ការបញ្ចូលទៅតាមដំណាក់កាល នូវថាមពលកកើតឡើងវិញ (ថាមពលព្រះអាទិត្យ និងថាមពលខ្យល់) និងវិធានការគ្រប់គ្រងប្រសិទ្ធភាពថាមពល។
- រដ្ឋាភិបាលនៃបណ្ដាប្រទេសនៅក្នុងអាងទន្លេមេគង្គ គួរបើកចំហព័ត៌មានពាក់ព័ន្ធ និងឯកសារពាក់ព័ន្ធ ដែលទាក់ទងនឹងសំណើគម្រោងទំនប់វារីអគ្គិសនីនានានៅលើតួមេនៃទន្លេមេគង្គ ហើយគួរធានាថា សមាជិកសហគមន៍រងគ្រោះ និងអ្នកពាក់ព័ន្ធដទៃទៀត អាចចូលរួមប្រកបដោយប្រសិទ្ធភាព និងពេញលេញនៅក្នុងការពិគ្រោះយោបល់ និងដំណើរការធ្វើសេចក្ដីសម្រេច។
- ព័ត៌មានអំពីគម្រោងទំនប់ថាមពលវារីអគ្គិសនី ដែលរួមទាំង ជាភាសាជាតិ គួរតែបានចាត់ចែងឲ្យមាននៅក្នុងមជ្ឈដ្ឋានសាធារណៈ ឬ ក្នុងគេហទំព័ររបស់គណៈកម្មការទន្លេមេគង្គ ដើម្បីធានាថា សាធារណជនអាចទទួលបានព័ត៌មាននេះ។
- លំហសម្រាប់សហគមន៍រងគ្រោះ និងអង្គការសង្គមស៊ីវិលនៅក្នុងការពិគ្រោះយោបល់ គួរត្រូវបានពង្រីក ជាពិសេសសម្រាប់អ្នកដែលធ្វើការផ្ទាល់ជាមួយសហគមន៍រងគ្រោះដោយសារទំនប់ និងផ្ដល់ពេលវេលាគ្រប់គ្រាន់ សម្រាប់ពួកគាត់ ដើម្បីធ្វើកិច្ចការនេះ និងផ្ដល់យោបល់លើសំណើគម្រោងទាំងនោះ។
- ការធ្វើសេចក្ដីសម្រេចអំពីគម្រោងថាមពលវារីអគ្គិសនី មិនគួរធ្វើឡើង ដាច់ដោយឡែកទៅតាមករណីគម្រោងនីមួយៗដាច់ពីគ្នា ដោយមិនគិតអំពីផលប៉ះពាល់រួម និងនៅទូទាំងអាងទន្លេនោះឡើយ។ គួរតែមានការធានាថា របកគំហើញនៃការសិក្សារបស់ក្រុមប្រឹក្សានៃគណៈកម្មការទន្លេមេគង្គ និងការសិក្សានានាផ្សេងទៀត នៅទូទាំងអាងទន្លេនេះ ដែលផ្ដល់នូវការវាយតម្លៃអំពីការបាត់បង់ និងសម្បទានវាងគ្នា ដែលជាប់ពាក់ព័ន្ធនឹងគម្រោងទាំងនេះ ត្រូវបានប្រើប្រាស់ជាព័ត៌មានប្រកបដោយអត្ថន័យ សម្រាប់ការធ្វើសេចក្ដីសម្រេច អំពីគម្រោងទំនប់ថាមពលវារីអគ្គិសនីនីមួយៗ។
- រដ្ឋាភិបាលនៃបណ្ដាប្រទេសនៅក្នុងអាងទន្លេមេគង្គ គួរស្វែងរកជម្រើសថាមពលផ្សេង ដែលមិនបំផ្លាញសង្គម និងបរិស្ថាន។ ថាមពលកកើតឡើងវិញ ដូចជា ថាមពលព្រះអាទិត្យ និងថាមពលខ្យល់ គួរត្រូវបានទទួលការពិចារណា និងបានបញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ថាមពល ដោយសារជម្រើសថាមពលជំនួសទាំងនេះ គឺជាដំណោះស្រាយសមស្របបំផុតសម្រាប់ប្រទេសយើង និងក្នុងតំបន់នេះ។ យើងអំពាវនាវដល់រដ្ឋាភិបាលក្នុងតំបន់នេះឲ្យចាត់ជាអាទិភាពនូវការបញ្ចូលបច្ចេកវិទ្យាថាមពលអគ្គិសនីកកើតឡើងវិញតាមបែបវិមជ្ឈការ ដែលមានកាន់តែច្រើនឡើងក្នុងតម្លៃប្រកួតប្រជែង ដោយមិនបង្កផលប៉ះពាល់អវិជ្ជមានចំពោះសង្គម និងបរិស្ថានដូចទំនប់ថាមពលវារីអគ្គិសនីខ្នាតធំឡើយ។
- រដ្ឋាភិបាលនៃបណ្ដាប្រទេសក្នុងតំបន់មេគង្គ គួរអនុម័តច្បាប់ និងការប្ដេជ្ញាប្រើប្រាស់អភិក្រមប្រព័ន្ធអេកូឡូស៊ីសម្រាប់ការគ្រប់គ្រងជលផល (EAFM) ដើម្បីថែរក្សាធនធានជលផលឲ្យមាននិរន្តរភាព និងការពារទីជម្រក និងកន្លែងពងកូនសំខាន់ៗផងដែរ។

- រដ្ឋាភិបាលគួរពិចារណាវិធានការគ្រប់គ្រងលើតម្រូវការ និងប្រសិទ្ធភាពថាមពល នៅក្នុងផែនការអភិវឌ្ឍន៍ថាមពលរបស់ខ្លួន។
- រដ្ឋាភិបាលនៃបណ្ដាប្រទេសនៅក្នុងអាងទន្លេមេគង្គ គួរបន្ថែមការយកចិត្តទុកដាក់ និងបង្កើនថវិកាសម្រាប់គម្រោងកម្មវិធីថែរក្សាតំបន់ព្រៃទឹកជំរាលទឹកភ្លៀងនៃតំបន់ទន្លេមេគង្គ ដែលជាប្រភពមេទឹក ដែលអាចធានានូវនិរន្តរភាពទឹកប្រើប្រាស់សម្រាប់ប្រជាជនតំបន់ទន្លេមេគង្គទាំងមូល។

**បញ្ជីឈ្មោះអង្គការមិនមែនរដ្ឋាភិបាល ដែលគាំទ្រសេចក្ដីថ្លែងការណ៍នេះ**

១) វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្ដីពីកម្ពុជា (NGOF)
២) សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ (CEPA)
៣) សម្ព័ន្ធភាពអភិរក្សជលផល (FACT)
៤) ភូមិខ្ញុំ (MVi)
៥) បណ្ដាញការពារទន្លេ៣ស (3SPN)
៦) អ្នកថែរក្សាទឹកបឹងទន្លេសាប (TSW)
៧) សម្ព័ន្ធភាពប្រជានេសាទកម្ពុជា (CCF)
៨) អង្គការអភិវឌ្ឍជនបទភូមិភាគពាយ័ព្យសាន (NRD)
៩) អ្នកស្ម័គ្រចិត្តដើម្បីសង្គមកម្ពុជា (CVS)
១០) អង្គការសង្គ្រោះជនងាយរងគ្រោះកម្ពុជា (SVC)
១១) សមាគមយុវជនជនជាតិដើមកម្ពុជា (CIYA)
១២) មជ្ឈមណ្ឌលម្លប់ព្រហ្មវិហារធម៌ (MPC)
១៣) កម្មវិធីផ្លាស់ប្តូរអនុផលព្រៃឈើ (NTFP-EP)
១៤) អ្នកអភិវឌ្ឍន៍សហគមន៍ (NAS)
១៥) ក្រុមអភិវឌ្ឍន៍ជនបទកម្ពុជា (CRDT)
១៦) អង្គការទឹកដីសុវណ្ណភូមិ (TDSP)
១៧) អង្គការនាគព័ន្ធសំរាប់ការអភិវឌ្ឍ (NOD)
១៨) អង្គការសកម្មភាពដើម្បីសុខមាលភាពស្ត្រីកម្ពុជា (KWWA)
១៩) អង្គការអភិវឌ្ឍន៍សហគមន៍កម្ពុជា (CCD-Kratie)